រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩២៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាន់ខ្ពស់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនឯកឧត្តម **ប្រាជ្ញ សុចិន្តា** អត្តលេខ ៦៣២៩១ នាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៧៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាន់ខ្ពស់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **សារិន សារីណា** អត្តលេខ ៥៧៩៧៧

២- លោកវរសេនីយ៍ទោ **ឃូ សុធារិទ្ធ** អត្តលេខ ១៤៩៩៩ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩២៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ ស្តីពី ការបង្កើត គណៈវិស្វករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈវិស្វករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៣ ស្តីពីការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា
- យោងតាមសំណើរបស់គណៈវិស្វករកម្ពុជា

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០៣រូប ជាអគ្គនាយករងមន្ទីរពិសោធន៍នៃគណៈវិស្វករកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

១- លោក **អ៊ុំ សុមន្ថា**
២- លោក **ស៊ូ ផល្លី**
៣- លោក **លី សុវណ្ណារិទ្ធ**

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គលេខាធិការគណៈវិស្វករកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩២៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### <u>សម្រេច</u>

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់សេនា** ជូនលោក ISOME Yasuo អ្នកជំនាញការរយៈពេលវែង JICA អមអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការគាំទ្រការអនុវត្តកម្មវិធីកំណែទម្រង់និងទំនើបកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យទទួលបានលទ្ធផលល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ៈ** តែងតាំងលោកវរសេនីយ៍ឯក **សាន ហាក់ អត្តលេខ ០១៥៧៥** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៧០ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្ដីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្ដូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

## សម្រេច

**មាត្រា ១ :** ប្រគល់ភារកិច្ចជូនលោក **លី ចន្ថា** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា RNK នៃក្រសួងព័ត៌មាន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៣១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **អឿន សារុន អត្តលេខ ០១៥៨៦** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩៧២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ឈន សារាភ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣០ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់របៀបរបបការងារ និង ការបែងចែកភារកិច្ច របស់រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** កំណត់របៀបរបបការងារ និង បែងចែកភារកិច្ច ជូនរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដូចតទៅ ៖

១-ឯកឧត្តម **ហ៊ូ សិទ្ធី** : ទទួលបន្ទុកជានាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ។

២-ឯកឧត្តម **សុខ ចិន្តាសោភា** : ទទួលបន្ទុកជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៣-ឯកឧត្តម ម៉ម សារិន : ទទួលបន្ទុកជួយសម្តេចនាយករដ្ឋមន្ត្រីក្នុងកិច្ចការសម្របសម្រួលទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយនឹងអង្គការនីតិបញ្ញត្តិ ។

៤-ឯកឧត្តម ស្រ៊ី ថាមរុទ្ធ : ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ក្នុងការសម្របសម្រួលកិច្ចការទំនាក់ទំនងអន្តរជាតិ ។

៥-ឯកឧត្តម ម៉ៅ សុវណ្ណា : ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី លើកិច្ចការដែលនាយករដ្ឋមន្ត្រីប្រគល់ជូនតាមករណីនីមួយៗ។

៦-ឯកឧត្តម ឈៀង យ៉ាំណារ៉ា : ទទួលបន្ទុកជាអគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ជាអគ្គលេខាធិការនៃគណកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា ។

៧-ឯកឧត្តម ឌុល គឿន : ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី លើកិច្ចការដែលនាយករដ្ឋមន្ត្រីប្រគល់ជូនតាមករណីនីមួយៗ។

៨-ឯកឧត្តម យូ ស៊ីនឡុង : ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី លើកិច្ចការដែលនាយករដ្ឋមន្ត្រីប្រគល់ជូនតាមករណីនីមួយៗ។

៩-ឯកឧត្តម អូស្មាន ហាសាន់ : ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី លើកិច្ចការដែលនាយករដ្ឋមន្ត្រីប្រគល់ជូនតាមករណីនីមួយៗ។

១០-ឯកឧត្តម សោម សឿន : ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីក្នុងការសម្របសម្រួលទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយនឹង បណ្តាគណៈបក្សនយោបាយ និង អង្គការសង្គមស៊ីវិល ។

១១-ឯកឧត្តម សុន គន្ធរ : ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី លើកិច្ចការសហគ្រាសធុនតូច និងមធ្យម និង មីក្រូហិរញ្ញវត្ថុ។

១២-ឯកឧត្តម ហ្សាការីយ៉ា អាដាម : ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ក្នុងកិច្ចការសាសនា ។

១៣-ឯកឧត្តម តៅ គឹមហួន : ទទួលបន្ទុកជួយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ក្នុងកិច្ចការបរទេស និង អាស៊ាន ។

**ប្រការ ២** : រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀត ដែលនាយករដ្ឋមន្ត្រី ប្រគល់ជូន ។

**ប្រការ ៣** : រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ១រូបៗ មានជំនួយការ ៤រូប ក្នុងនោះ ១រូប មានឋានៈស្មើ អគ្គនាយក, ១រូប មានឋានៈស្មើអគ្គនាយករង និង ២រូប មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**ប្រការ ៤** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥ :** ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្ត តាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ដូចប្រការ ១ និង ប្រការ ៥*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៤ សរ

# សារាចរ

## ស្តីពី

## ការផ្អាកការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ

អនុវត្តតាមសារាចរណែនាំលេខ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ បុណ្យអន្តរជាតិ ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលតែងតែប្រារព្ធ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុកចំនួន៣ថ្ងៃ ដើម្បីអបអរសាទរព្រះរាជពិធីបុណ្យប្រពៃណីជាតិ និងបន្តរក្សាទំនៀមទម្លាប់ដ៏ប្រពៃរបស់ប្រជាជាតិខ្មែរ ដែលមានតាំងពីយូរលង់មកហើយ។ ក្នុងឱកាសដ៏មហោឡារិកនេះ រាជរដ្ឋាភិបាលបានរៀបចំពិធីប្រណាំងទូកង បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅតាមដងទន្លេសាប មុខព្រះបរមរាជវាំង រាជធានីភ្នំពេញ។ ដោយឡែក នៅតាមបណ្តាខេត្ត និងស្រុកមួយចំនួនក៏បានរៀបចំពិធីនេះផងដែរ។

ដោយសារឆ្នាំនេះ ស្ថានភាពទឹកជំនន់នៃទន្លេមេគង្គមានសភាពធ្ងន់ធ្ងរ ដែលបណ្តាលឱ្យសាលារៀន វត្តអារាម មន្ទីរពេទ្យ ផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ ផលដំណាំ និងសត្វពាហនៈជាច្រើនត្រូវរងការបំផ្លិចបំផ្លាញ និងធ្វើឱ្យប្រជាពលរដ្ឋនៅតំបន់រងការលិចលង់មួយចំនួនបាត់បង់ជីវិតផងដែរ។ ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវជាតិ ផ្លូវលំជនបទ ស្ពាន ប្រព័ន្ធធារាសាស្ត្រតូចធំ ត្រូវបានកាត់ផ្តាច់ និងរងការខូចខាតយ៉ាងដំណំ។ លើសពីនេះទៀត ស្ថានភាពកម្ពស់ទឹកនៅតែស្ថិតក្នុងកម្រិត ដែលត្រូវប្រុងប្រយ័ត្ន និងត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ ដើម្បីជៀសវាងនូវគ្រោះថ្នាក់ផ្សេងៗដែលអាចកើតឡើងដោយចៃដន្យ។

ដើម្បីប្រមូលផ្តុំកម្លាំងសរុប មធ្យោបាយសរុប សម្រាប់ដោះស្រាយរាល់បញ្ហាប្រឈមនេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំ ដូចតទៅៈ

១. ផ្អាកការរៀបចំព្រះរាជពិធីអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅតាមដងទន្លេសាបមុខព្រះបរមរាជវាំងរាជធានីភ្នំពេញ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦ ១៧ និង១៨ ខែវិច្ឆិកា ឆ្នាំ២០១៣។

២. ការរៀបចំព្រះរាជពិធីអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅតាមទីកន្លែងដទៃទៀតអាចប្រព្រឹត្តទៅជាធម្មតា តាមទំនៀមទម្លាប់ប្រពៃណី និងតាមលទ្ធភាពរបស់ប្រជាពលរដ្ឋ។

៣. ការឈប់សម្រាករបស់មន្ត្រីរាជការ និយោជិតកម្មករ ចំនួន៣ថ្ងៃក្នុងព្រះរាជពិធីនេះ នៅរក្សាដដែល ដូចខ្លឹមសារដែលមានចែងក្នុងអនុក្រឹត្យលេខ១៨៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិតកម្មករ ប្រចាំឆ្នាំ២០១៣។

៤. គ្រប់ក្រសួង ស្ថាប័ន រាជធានី និងខេត្ត ត្រូវបន្តយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ក្នុងការជួយសង្គ្រោះដល់ប្រជាពលរដ្ឋរងគ្រោះ ដើម្បីដោះស្រាយកង្វះខាតស្បៀង ជម្រក ថ្នាំពេទ្យ និងត្រូវយកចិត្តទុកដាក់ក្នុងការស្តារឡើងវិញនូវដំណាំស្រូវ ដំណាំផ្សេងៗ និងហេដ្ឋារចនាសម្ព័ន្ធដែលបានរងការខូចខាត។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិអន្តរជាតិ និងរាជធានីខេត្ត ត្រូវចាត់ចែងផ្សព្វផ្សាយនិងអនុវត្តឱ្យមានប្រសិទ្ធភាព ដោយស្មារតី ទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់សាលារាជធានី ខេត្ត*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ១១ សារាចរ

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំទិវាមនុស្សចាស់កម្ពុជា និង ទិវាមនុស្សចាស់អន្តរជាតិ ១ តុលា

រាជរដ្ឋាភិបាលបានរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិថ្ងៃទី ១ ខែ តុលា ជារៀងរាល់ឆ្នាំ ស្របតាមគោលនយោបាយជាតិសម្រាប់មនុស្សចាស់ នៃព្រះរាជាណាចក្រកម្ពុជា និង សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ។ ការប្រារព្ធទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី ១ ខែតុលា មានគោលបំណងលើកកម្ពស់កិច្ចគាំពារដ៏មានប្រសិទ្ធភាពសំដៅលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ឱ្យបានល្អប្រសើរ ហើយទិវានេះក៏បង្ហាញឱ្យឃើញពីតួនាទីដ៏សំខាន់របស់មនុស្សចាស់នៅក្នុងសង្គមជាតិមនុស្សចាស់ជាបុព្វការីជន ដែលបានបង្កើតធនធានដ៏មានសារប្រយោជន៍ ព្រមទាំងផ្តល់នូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍យ៉ាងច្រើនឥតគណនា សម្រាប់មនុស្សជំនាន់ក្រោយ ។ ជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់ចំពោះមនុស្សចាស់កម្ពុជា រាជរដ្ឋាភិបាលបានបង្កើតឱ្យមានគណៈកម្មាធិការជាតិកម្ពុជា ដើម្បីមនុស្សចាស់ សម្រាប់អនុវត្តនូវតួនាទី និងភារកិច្ច ដែលមានជាអាទិ៍ រៀបចំគោលនយោបាយជាតិ ដើម្បីលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ និងរៀបចំទិវាមនុស្សចាស់នៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់យកថ្ងៃទី ១ ខែ តុលា ជារៀងរាល់ឆ្នាំ រួមជាមួយនឹងទិវាមនុស្សចាស់អន្តរជាតិ ។

រាជរដ្ឋាភិបាលបានចាត់ទុកទិវាមនុស្សចាស់កម្ពុជា និង ទិវាមនុស្សចាស់អន្តរជាតិ ជាទិវាបុណ្យរម្លឹកដល់គុណូបការៈរបស់មនុស្សចាស់កម្ពុជា ជីដូន ជីតា ឪពុក ម្តាយ អ៊ុំ ពូ មីង ដែលបានកសាងបន្សល់ទុកនូវកេរមរតកដ៏ថ្លៃថ្លាសម្រាប់កូនចៅជំនាន់នេះ និងជំនាន់ក្រោយៗទៀតរបស់សង្គមកម្ពុជា ។ ដើម្បីរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៣ ឱ្យបានទូលំទូលាយ និងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់វ័យទាំងអស់បានយល់ដឹងកាន់តែច្បាស់អំពីអត្ថន័យនៃទិវានេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង- ស្ថាប័ន និងគ្រប់រាជធានី ខេត្ត ដូចតទៅ÷

១. ប្រធានបទនៃទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៣ ត្រូវបានកំណត់ថា ***«គោរពដឹងគុណមនុស្សចាស់គឺជាកតញ្ញុតាធម៌ គ្រួសារមានសុភមង្គល សង្គមរីកចម្រើន»*** ។

២. ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ត្រូវសហការជាមួយក្រសួង- ស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិ ដើម្បីចាត់តាំងមិទ្ទិញអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ នេះ ឱ្យបានអធិកអធម ។

៣. នៅរាជធានី ខេត្តត្រូវរៀបចំមិទ្ទិញអបអរសាទរទិវាមនុស្សចាស់កម្ពុជា និង ទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៣ នេះ ដោយបង្កលក្ខណៈឱ្យមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ព្រះសង្ឃ បុព្វជិត លោកយាយ លោកតា ព្រមទាំងប្រជាជនគ្រប់វ័យមានឱកាសចូលរួម ដើម្បីយល់ដឹងអំពីសារសំខាន់នៃគោលនយោបាយ-ជាតិចំពោះមនុស្សចាស់កម្ពុជា ។

៤. អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ សូមបន្តជួយដល់សកម្មភាពកម្មវិធីអភិវឌ្ឍសមាគមមនុស្សចាស់ដែលមានស្រាប់ និងគាំទ្រការបង្កើតនៅតាមសហគមន៍មូលដ្ឋានគ្រប់ឃុំ- សង្កាត់ ដែលពុំទាន់បានបង្កើតសមាគមមនុស្សចាស់ ត្រូវបង្កើតឱ្យមានសមាគមមនុស្សចាស់មួយ ក្នុងមូលដ្ឋានឃុំ- សង្កាត់របស់ខ្លួន ដើម្បីបង្កើនស្មារតីសាមគ្គីជួយគ្នាទៅវិញទៅមករវាងមនុស្សចាស់ទូទៅ ជាពិសេសយកចិត្តទុកដាក់ជួយមនុស្សចាស់ជរា ពិការ និងទុរគតជន ។ល។

៥. គ្រប់ក្រសួង- ស្ថាប័ន និងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំកម្មវិធីចុះសួរសុខទុក្ខ និង សំណេះ-សំណាលជាមួយមនុស្សចាស់នៅតាមមូលដ្ឋាន វត្តអារាម វិហារសាសនានានា ដោយនាំយកជំនួយឧបត្ថម្ភតាមសទ្ធាជ្រះថ្លា ជួយដល់មនុស្សចាស់ជរា ពិការ និងទុរគតជន ។ល។

៦. ក្រសួងធម្មការ និងសាសនាត្រូវធ្វើការណែនាំចលនាតាមវត្តអារាម វិហារសាសនានៅទូទាំងប្រទេសដល់បុព្វជិតសាសនា ដើម្បីឱ្យមានសកម្មភាពជួយឧបត្ថម្ភមនុស្សចាស់ជរា ពិការ និងទុរគតជនដែលគ្មានទីពឹង ។

៧. ក្រសួងព័ត៌មាន ត្រូវណែនាំគ្រប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍របស់រដ្ឋ ឯកជន និងគ្រប់ភ្នាក់ងារសារព័ត៌មានទាំងអស់ជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវខ្លឹមសារសកម្មភាព ក្នុងឱកាសទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ នេះ ។

៨. គ្រប់ក្រសួង- ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំបដានៅអង្គភាព និងទីសាធារណៈ តាមខ្លឹមសារដូចតទៅ÷

- **ជយោ ព្រះរាជាណាចក្រកម្ពុជា !**
- **អបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី ១ ខែ តុលា !**
- **មនុស្សចាស់នៅតែជាធនធានដ៏សំខាន់ក្នុងការអភិវឌ្ឍគ្រួសារ និងសង្គមជាតិ !**
- **គោរពដឹងគុណមនុស្សចាស់ គឺជាកតញ្ញុតាធម៌ គ្រួសារមានសុភមង្គល សង្គមរីកចម្រើន !**
- **កសាងសង្គមដែលមានការអភិវឌ្ឍសម្រាប់មនុស្សគ្រប់វ័យ !**

៩. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ គណៈ-កម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិត្រូវធ្វើការណែនាំអនុវត្តតាមសារាចរណែនាំនេះ និងបូកសរុបលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

គ្រប់ក្រសួង- ស្ថាប័ន រាជធានី- ខេត្ត ត្រូវអនុវត្តសារាចរណែនាំនេះដោយស្មារតីទទួលខុសត្រូវខ្ពស់ និងឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**ចម្លងជូន :**</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *គ្រប់ក្រសួង ស្ថាប័ន*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *សាលារាជធានី- ខេត្ត*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១២ សរណន

# សារាចរណែនាំ
# ស្តីពី
# ការតែងតាំងមន្ត្រីខុទ្ទកាល័យ និងជំនួយការថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់

អនុលោមតាមព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី អនុក្រឹត្យ លេខ ២០ អនក្រ បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន និងបណ្តាលិខិតបទដ្ឋានផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់កន្លងមក និងដើម្បីគ្រប់គ្រងមន្ត្រីរាជការគ្រប់ប្រភេទឲ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសមន្ត្រីដែលបំពេញមុខងារនៅក្នុងខុទ្ទកាល័យរបស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៅតាមក្រសួង និងស្ថាប័ននានារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី ៥ នៃរដ្ឋសភា ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ សូមធ្វើការណែនាំដូចតទៅ :

១-រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នត្រូវរៀបចំចេញប្រកាសបញ្ចប់តំណែងមន្ត្រីខុទ្ទកាល័យ ទីប្រឹក្សា និងជំនួយការដែលបំពេញការងារក្នុងសាមី ខុទ្ទកាល័យ - អមសាមី ក្រសួង ស្ថាប័ន និងក្នុងអង្គភាពចំណុះសាមីក្រសួង ស្ថាប័នទាំងអស់ ដែលទទួលបានការតែងតាំងមុនថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ។

២-ក្រោយពីបានបញ្ចប់តំណែងរជនទាំងអស់ដូចមានចែងក្នុងចំណុចទី ១ ខាងលើ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នអាចរៀបចំតែងតាំងសាជាថ្មី នូវមន្ត្រីខុទ្ទកាល័យ ទីប្រឹក្សា និងជំនួយការឲ្យបំពេញការងារក្នុងសាមីខុទ្ទកាល័យ - អមសាមីក្រសួង ស្ថាប័ន ឡើងវិញស្របតាមអនុក្រឹត្យលេខ ២០ អនក្រ បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ទទួលបានសារាចរណែនាំនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារខាងលើ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........សហវ.

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០១៣

# ប្រកាស
# ស្តីពីការបង្វែរឥណទានជូនរដ្ឋបាលក្រុង ស្រុកនៃខេត្តសៀមរាប សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ៦២៩ សហវ.ប្រក.ហម ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ២៧៦អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៦៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីការបង្កើនបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃក្របខ័ណ្ឌ ឃ, ក្របខ័ណ្ឌ គ ឋានន្តរស័ក្តិទី៣ និងក្របខ័ណ្ឌ គ ឋានន្តរស័ក្តិទី២ ក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុង ស្រុក
- បានឃើញប្រកាសលេខ២០៣ ប្រក សហវ.ថ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ជាថវិកាខេត្ត ក្រុង
- បានឃើញសារាចរណែនាំលេខ០០៨សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៣
- បានឃើញប្រកាសលេខ២៨៥ សហវ.ហម ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១០៤៧ សហវ.ហម ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១២ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូល និងការបែងចែកឥណទានចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញសេចក្តីជូនដំណឹងលេខ០០៣ សហវ.ហម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ ស្តីពីការអនុវត្តចំណាយថវិកាក្រុង ស្រុក សម្រាប់ឆ្នាំ២០១៣
- យោងសំណើលេខ ០៩២/១៣ អ.ជ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកអង្គរជុំ
- យោងសំណើលេខ ៤០៥ សអធ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកអង្គរធំ
- យោងសំណើលេខ ២៣៥ សបស ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ របស់សាលាស្រុកបន្ទាយស្រី
- យោងសំណើលេខ ០០១/១៣ សណ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកជីក្រែង
- យោងសំណើលេខ ៣៧ សកឡ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកក្រឡាញ់
- យោងសំណើលេខ ៦២ ស្រព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកពួក
- យោងសំណើលេខ ១០៨ លស ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកប្រាសាទបាគង
- យោងសំណើលេខ ១៥៩ ស.ណ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ របស់សាលាក្រុងសៀមរាប
- យោងសំណើលេខ ២៧៦/១៣ សនគ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ របស់សាលាស្រុកសូទ្រនិគម
- យោងសំណើលេខ ៦៧០ សសសស ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកស្រីស្នំ
- យោងសំណើលេខ ០៩០/១៣ រប.សស្វល ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ របស់សាលាស្រុកស្វាយលើ
- យោងសំណើលេខ ៤២០/១៣ សវរ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ របស់សាលាស្រុកវ៉ារិន
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់រដ្ឋបាលក្រុង ស្រុកនៃខេត្តសៀមរាប សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ នូវការបង្វែរឥណទានដូចមានក្នុងតារាងខាងក្រោមនេះ ៖

ឯកតា: ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៣ | ឥណទានកែប្រែ | | ឥណទានថ្មី |
|---|---|---|---|---|---|---|---|
| | | | | | កើន | ថយ | |
| 1-ស្រុកអង្គរជុំ | | | | | | | |
| 62 | 622 | 6227 | ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 200 | | 200 | 0 |
| | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 4,500 | 3,032 | | 7,532 |
| | | 6242 | សោហ៊ុយបេសកកម្ម | 1,600 | 1,164 | | 2,764 |
| | | 6243 | សោហ៊ុយស្នាក់នៅ | 7,000 | 3,560 | | 10,560 |
| | 626 | 6262 | សោហ៊ុយទូរគមនាគមន៍ | 2,000 | | 2,000 | 0 |
| 64 | 641 | 6411 | ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ | 6,400 | | 40 | 6,360 |
| | | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 3,700 | 450 | | 4,150 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 101,000 | 11,399 | | 112,399 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 6422 | ប្រាក់បំណាច់មុខងារ | 8,100 | 52 | | 8,152 |
| | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ | 1,900 | | 80 | 1,820 |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | 1,900 | | 28 | 1,872 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | កូនមានអាយុតិចជាង១៥ឆ្នាំ | 1,700 | | 205 | 1,495 |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 1,400 | | 104 | 1,296 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 17,000 | | 17,000 | 0 |
| | | | **សរុប** | **158,400** | **19,657** | **19,657** | **158,400** |
| 2-ស្រុកអង្គរធំ | | | | | | | |
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 3,100 | 1,600 | | 4,700 |
| | | 6242 | សោហ៊ុយបេសកកម្ម | 1,400 | 920 | | 2,320 |
| | | 6243 | សោហ៊ុយស្នាក់នៅ | 3,500 | 1,675 | | 5,175 |
| 64 | 641 | 6411 | ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ | 6,400 | 87 | | 6,487 |
| | | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 2,300 | | 684 | 1,616 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 78,900 | 10,131 | | 89,031 |
| | | 6422 | ប្រាក់បំណាច់មុខងារ | 7,400 | 1,176 | | 8,576 |
| | | 6424 | ប្រាក់បំណាច់តំបន់ | 400 | | 4 | 396 |
| | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ | 1,900 | | 220 | 1,680 |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | 1,900 | | 28 | 1,872 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | កូនមានអាយុតិចជាង ១៥ ឆ្នាំ | 2,400 | | 405 | 1,995 |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 1,400 | | 248 | 1,152 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 14,000 | | 14,000 | 0 |
| | | | **សរុប** | **125,000** | **15,589** | **15,589** | **125,000** |
| 3-ស្រុកបន្ទាយស្រី | | | | | | | |
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 4,600 | 4,500 | | 9,100 |
| | | 6242 | សោហ៊ុយបេសកកម្ម | 1,000 | 1,000 | | 2,000 |
| | | 6243 | សោហ៊ុយស្នាក់នៅ | 5,600 | 5,500 | | 11,100 |
| 64 | 641 | 6411 | ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ | 6,500 | 1,816 | | 8,316 |
| | | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 3,600 | 1,026 | | 4,626 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 101,400 | 330 | | 101,730 |
| | | 6422 | ប្រាក់បំណាច់មុខងារ | 6,400 | 280 | | 6,680 |
| | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ | 1,700 | | 20 | 1,680 |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | 1,900 | | 28 | 1,872 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | កូនមានអាយុតិចជាង ១៥ ឆ្នាំ | 900 | | 500 | 400 |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 1,300 | | 500 | 800 |
| | | 6454 | ឧបត្ថម្ភនិវត្តជន | 4,500 | | 2,404 | 2,096 |
| 65 | 652 | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ | 2,000 | 4,000 | | 6,000 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 09 | | | ចំណាយមិនបានគ្រោងទុក | 15,000 | | 15,000 | 0 |
| | | | **សរុប** | **156,400** | **18,452** | **18,452** | **156,400** |
| 4-ស្រុកជីក្រែង | | | | | | | |
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 3,300 | 2,304 | | 5,604 |
| | | 6242 | សោហ៊ុយបេសកកម្ម | 2,200 | 2,304 | | 4,504 |
| | | 6243 | សោហ៊ុយស្នាក់នៅ | 9,400 | 2,304 | | 11,704 |
| 64 | 642 | 6421 | បៀវត្សមូលដ្ឋាន | 102,000 | 10,827 | | 112,827 |
| | | 6422 | ប្រាក់បំណាច់មុខងារ | 9,300 | 3,261 | | 12,561 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 21,000 | | 21,000 | 0 |
| | | | **សរុប** | **147,200** | **21,000** | **21,000** | **147,200** |
| 5-ស្រុកក្រឡាញ់ | | | | | | | |
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 2,700 | 2,400 | | 5,100 |
| | | 6242 | សោហ៊ុយបេសកកម្ម | 1,500 | 1,024 | | 2,524 |
| | | 6243 | សោហ៊ុយស្នាក់នៅ | 7,100 | 6,690 | | 13,790 |
| 64 | 641 | 6411 | ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ | 6,300 | 996 | | 7,296 |
| | | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 9,300 | 12 | | 9,312 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 106,500 | 7,197 | | 113,697 |
| | | 6422 | ប្រាក់បំណាច់មុខងារ | 8,100 | 153 | | 8,253 |
| | | 6424 | ប្រាក់បំណាច់តំបន់ | 500 | | 14 | 486 |
| | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ | 1,700 | | 20 | 1,680 |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | 1,900 | | 28 | 1,872 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | កូនមានអាយុតិចជាង ១៥ ឆ្នាំ | 1,800 | | 590 | 1,210 |
| | | | កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ | 300 | | 300 | 0 |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 1,600 | | 520 | 1,080 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 17,000 | | 17,000 | 0 |
| | | | **សរុប** | **166,300** | **18,472** | **18,472** | **166,300** |
| 6-ស្រុកពួក | | | | | | | |
| 64 | 641 | 6411 | ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ | 6,400 | 300 | | 6,700 |
| | | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 4,300 | 300 | | 4,600 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 152,300 | 20,950 | | 173,250 |
| | | 6422 | ប្រាក់បំណាច់មុខងារ | 11,500 | 3,250 | | 14,750 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 1,500 | 100 | | 1,600 |
| | | 6454 | ឧបត្ថម្ភនិវត្តជន | 2,900 | | 2,900 | 0 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 22,000 | | 22,000 | 0 |
| | | | **សរុប** | **200,900** | **24,900** | **24,900** | **200,900** |
| 7-ស្រុកប្រាសាទបាគង | | | | | | | |
| 60 | 606 | 6061 | អគ្គិសនី | 3,700 | | 3,700 | 0 |
| 64 | 641 | 6411 | ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ | 6,400 | 500 | | 6,900 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 3,500 | 510 | | 4,010 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 109,100 | 9,878 | | 118,978 |
| | | 6422 | ប្រាក់បំណាច់មុខងារ | 9,000 | 1,500 | | 10,500 |
| | | 6424 | ប្រាក់បំណាច់តំបន់ | 500 | | 26 | 474 |
| | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ | 1,900 | | 220 | 1,680 |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | 2,000 | | 128 | 1,872 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | កូនមានអាយុតិចជាង ១៥ ឆ្នាំ | 800 | | 120 | 680 |
| | | | កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ | 400 | | 400 | 0 |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 900 | 120 | | 1,020 |
| | | 6453 | មរណៈភាព | 2,400 | 286 | | 2,686 |
| 65 | 652 | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ | 4,000 | 8,800 | | 12,800 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 17,000 | | 17,000 | 0 |
| | | | **សរុប** | **161,600** | **21,594** | **21,594** | **161,600** |
| 8-ក្រុងសៀមរាប | | | | | | | |
| 61 | 615 | 6153 | ការថែទាំជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងប្រព័ន្ធលូ | 130,000 | 36,000 | | 166,000 |
| 64 | 641 | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 3,500 | 50 | | 3,550 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 204,200 | | 200 | 204,000 |
| | 645 | 6453 | មរណៈភាព | 2,500 | 150 | | 2,650 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 36,000 | | 36,000 | 0 |
| | | | **សរុប** | **376,200** | **36,200** | **36,200** | **376,200** |
| 9-ស្រុកសូទ្រនិគម | | | | | | | |
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 2,400 | 4,720 | | 7,120 |
| | | 6242 | សោហ៊ុយបេសកកម្ម | 1,300 | 1,888 | | 3,188 |
| 64 | 641 | 6411 | ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ | 6,400 | 492 | | 6,892 |
| | | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 3,500 | 336 | | 3,836 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 113,600 | 12,273 | | 125,873 |
| | | 6422 | ប្រាក់បំណាច់មុខងារ | 11,600 | | 745 | 10,855 |
| | | 6424 | ប្រាក់បំណាច់តំបន់ | 600 | | 42 | 558 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | កូនមានអាយុតិចជាង ១៥ ឆ្នាំ | 1,800 | | 465 | 1,335 |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 1,600 | | 232 | 1,368 |
| | | 6456 | គ្រោះថ្នាក់ការងារ និងទុព្វលភាព | 2,100 | | 2,100 | 0 |
| 65 | 652 | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ | 4,000 | 3,875 | | 7,875 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 20,000 | | 20,000 | 0 |
| | | | **សរុប** | **168,900** | **23,584** | **23,584** | **168,900** |
| 10-ស្រុកស្រីស្នំ | | | | | | | |
| 60 | 606 | 6061 | អគ្គិសនី | 5,600 | | 5,600 | 0 |
| | | 6062 | ទឹក | 1,000 | | 1,000 | 0 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 2,400 | 2,850 | | 5,250 |
| | | 6242 | សោហ៊ុយបេសកកម្ម | 1,000 | 1,180 | | 2,180 |
| | | 6243 | សោហ៊ុយស្នាក់នៅ | 5,600 | 5,970 | | 11,570 |
| 64 | 641 | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 3,800 | 53 | | 3,853 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 107,100 | | 3,703 | 103,397 |
| | | 6424 | ប្រាក់បំណាច់តំបន់ | 400 | 14 | | 414 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 900 | 36 | | 936 |
| | | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសម្រាលកូន | 300 | 3,600 | | 3,900 |
| 65 | 652 | 6528 | ចំណាយសង្គមផ្សេងៗទៀត | 0 | 6,600 | | 6,600 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 10,000 | | 10,000 | 0 |
| | | | **សរុប** | **138,100** | **20,303** | **20,303** | **138,100** |
| 11-ស្រុកស្វាយលើ | | | | | | | |
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 3,100 | 3,800 | | 6,900 |
| | | 6242 | សោហ៊ុយបេសកកម្ម | 1,400 | 1,479 | | 2,879 |
| | | 6243 | សោហ៊ុយស្នាក់នៅ | 4,500 | 4,720 | | 9,220 |
| 64 | 641 | 6411 | ប្រាក់បំណាច់អភិបាលក្រុង ស្រុក ខណ្ឌ | 6,400 | 3,356 | | 9,756 |
| | | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 3,600 | | 856 | 2,744 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 110,300 | | 4,490 | 105,810 |
| | | 6422 | ប្រាក់បំណាច់មុខងារ | 7,700 | 1,272 | | 8,972 |
| | | 6424 | ប្រាក់បំណាច់តំបន់ | 500 | | 66 | 434 |
| | 644 | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ | 1,700 | | 20 | 1,680 |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | 1,900 | | 28 | 1,872 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | កូនមានអាយុតិចជាង ១៥ ឆ្នាំ | 1,100 | | 135 | 965 |
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 1,200 | | 132 | 1,068 |
| | | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសម្រាលកូន | 1,300 | 1,100 | | 2,400 |
| 65 | 652 | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ | 4,000 | 6,000 | | 10,000 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 16,000 | | 16,000 | 0 |
| | | | **សរុប** | **164,700** | **21,727** | **21,727** | **164,700** |
| 12-ស្រុកវ៉ារិន | | | | | | | |
| 62 | 624 | 6241 | សោហ៊ុយដឹកជញ្ជូន | 5,800 | 4,165 | | 9,965 |
| | | 6242 | សោហ៊ុយបេសកកម្ម | 1,000 | 720 | | 1,720 |
| | | 6243 | សោហ៊ុយស្នាក់នៅ | 5,000 | 3,850 | | 8,850 |
| 64 | 641 | 6412 | ប្រាក់បំណាច់អភិបាលរងក្រុង ស្រុក ខណ្ឌ | 800 | 200 | | 1,000 |
| | 642 | 6421 | បៀវត្សមូលដ្ឋាន | 76,100 | 1,800 | | 77,900 |
| | | 6422 | ប្រាក់បំណាច់មុខងារ | 6,900 | 800 | | 7,700 |
| | 645 | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | | | | |
| | | | កូនមានអាយុតិចជាង ១៥ ឆ្នាំ | 1,000 | | 400 | 600 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 900 | | 240 | 660 |
| | | 6453 | មរណៈភាព | 9,500 | | 240 | 9,260 |
| 65 | 652 | 6528 | ចំណាយសង្គមផ្សេងៗទៀត | 0 | 3,345 | | 3,345 |
| 09 | | | ចំណាយមិនបានគ្រោងទុក | 14,000 | | 14,000 | 0 |
| សរុប | | | | 121,000 | 14,880 | 14,880 | 121,000 |
| **សរុបរួម** | | | | 2,084,700 | 256,358 | 256,358 | 2,084,700 |

**ប្រការ២:** អភិបាលនៃគណៈអភិបាលស្រុកអង្គរជុំ ស្រុកអង្គរធំ ស្រុកបន្ទាយស្រី ស្រុកជីក្រែង ស្រុកក្រឡាញ់ ស្រុកពួក ស្រុកប្រាសាទបាគង ក្រុងសៀមរាប ស្រុកសូទ្រនិគម ស្រុកស្រីស្នំ ស្រុកស្វាយលើ ស្រុកវ៉ារិន នៃខេត្តសៀមរាប ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
